# សេចក្តីថ្លែងការណ៍រួម
# រវាង
# ព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម

------------

១.តាមការអញ្ជើញរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម **ង្វៀន ស្វានហ្វ៊ុក** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងលោកជំទាវ បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់វៀតណាម មកបំពេញទស្សនកិច្ចផ្លូវការ នៅព្រះរាជាណាចក្រកម្ពុជា **ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៦ ខែ មេសា ឆ្នាំ២០១៧**។

ក្នុងឱកាសបំពេញទស្សនកិច្ច ឯកឧត្តមនាយករដ្ឋមន្ត្រី **ង្វៀន ស្វានហ្វ៊ុក** បានចូលក្រាបបង្គំគាល់ **ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា បានជួបពិភាក្សាការងារជាមួយ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និងសម្តែងការគួរសម **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា និង**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា ព្រមទាំងចូលថ្វាយបង្គំ**ព្រះអគ្គមហាសង្ឃរាជាធិបតី ទេព វង្ស សម្តេចព្រះមហាសង្ឃរាជគណៈមហានិកាយ** ។

ឯកឧត្តមនាយករដ្ឋមន្ត្រី **ង្វៀន ស្វានហ្វ៊ុក** ក៏បានអញ្ជើញទៅដាក់កម្រងផ្កានៅវិមានឯករាជ្យ **មណ្ឌប ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះវររាជបិតាជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ"** និងស្តូបអនុស្សាវរីយ៍មិត្តភាព**កម្ពុជា-វៀតណាម**។ ឯកឧត្តមនាយករដ្ឋមន្ត្រី **ង្វៀន ស្វានហ្វ៊ុក** ក៏បានអញ្ជើញទស្សនកិច្ចនៅស្ថានទូតវៀតណាម ប្រចាំកម្ពុជា ផងដែរ។

ក្នុងឱកាសនេះដែរ នាយករដ្ឋមន្ត្រីនៃប្រទេសទាំងពីរបានអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ស្ពានតភ្ជាប់ជ្រៃធំ (ខេត្តកណ្តាល ប្រទេសកម្ពុជា) និង ឡុង ប៊ិញ (ខេត្តអានយ៉ាង ប្រទេសវៀតណាម) និងធ្វើជាសាក្សីក្នុងពិធីចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នា ចំនួន ០៤ ដូចជា អនុស្សារណៈយោគយល់គ្នា **"ស្តីពីការសិក្សារួមស្តីពីការសាងសង់ផ្លូវល្បឿនលឿនភ្នំពេញ-បាវិត និងផ្លូវល្បឿនលឿនបូជីមិញ-ម៉ុកបៃ"** រវាងក្រសួងសាធារណការ និងដឹកជញ្ជូនកម្ពុជា និងក្រសួងដឹកជញ្ជូនវៀតណាម អនុស្សារណៈយោគយល់គ្នា **"ស្តីពីគម្រោងកសាងមជ្ឈមណ្ឌលផ្តល់សេវាកម្មព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ ដល់អ្នកញៀនគ្រឿងញៀន"** នៅខេត្តព្រះសីហនុ រវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាកម្ពុជា និងក្រសួងការងារ យុទ្ធជនពិការ និងកិច្ចការសង្គមវៀតណាម ការបន្តសុពលភាពនៃអនុស្សារណៈយោគយល់គ្នា **"ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីលើវិស័យជលផល"** រវាងរដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទកម្ពុជា និងនាយកដ្ឋានជលផលក្រសួងកសិកម្ម និងអភិវឌ្ឍន៍ជនបទវៀតណាម និងអនុស្សារណៈយោគយល់គ្នា **"ស្តីពីការឧបត្ថម្ភសាងសង់**

**មហាវិថីមិត្តភាពភ្នំពេញ-ហាណូយ**" រវាងរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋធានីហាណូយ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

២. ក្នុងបរិយាកាសសាមគ្គីភាព មិត្តភាព ការយោគយល់គ្នាទៅវិញទៅមក និងការទុកចិត្តគ្នា ថ្នាក់ដឹកនាំនៃប្រទេសទាំងពីរបានធ្វើការផ្លាស់ប្តូរទស្សនវិស័យស៊ីជម្រៅ ក្នុងការលើកកំពស់ទំនាក់ទំនងជាមិត្តភាព និងគ្រប់ជ្រុងជ្រោយរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ក៏ដូចជាបញ្ហាតំបន់ និងអន្តរជាតិ ដែលជាផលប្រយោជន៍រួម នៃប្រទេសទាំងពីរ។

ឯកឧត្តមនាយករដ្ឋមន្ត្រី **ង្វៀន សួនហ៊្វុក** បានកោតសរសើរចំពោះសមិទ្ធិផលសំខាន់ៗ ដែលប្រជាជនកម្ពុជា សម្រេចបានក្រោមការគ្រងរាជ្យសម្បត្តិប្រកបដោយក្តីមេត្តាករុណារបស់**ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** និងក្រោមការដឹកនាំរបស់ព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាលកម្ពុជា ដែលមាន**សម្តេចតេជោនាយករដ្ឋមន្ត្រី** ជាប្រមុខ ក្នុងបុព្វហេតុកសាង និងអភិវឌ្ឍជាតិដែលនឹងបន្តលើកកម្ពស់តួនាទី និងឋានៈកម្ពុជា នៅក្នុងតំបន់ និងពិភពលោក។ ក្នុងឱកាសនេះ ឯកឧត្តមនាយករដ្ឋមន្ត្រី **ង្វៀន សួនហ៊្វុក** បានសម្តែងនូវការជូនពរយ៉ាងស្មោះស្ម័គ្រ ឲ្យកម្ពុជាទទួលបានជោគជ័យក្នុងការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៤ នៅខែមិថុនា ឆ្នាំ២០១៧ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ នៅឆ្នាំ២០១៨ នាពេលខាងមុខ។

**សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** និងថ្នាក់ដឹកនាំកម្ពុជា បានកោតសរសើរចំពោះសមិទ្ធិផលដ៏ធំធេងដែលប្រជាជនវៀតណាមសម្រេចបានក្នុងការកែទម្រង់ កសាង និងអភិវឌ្ឍជាតិ និងជូនពរប្រជាជនវៀតណាម ក្រោមការដឹកនាំរបស់គណបក្សកុម្មុយនិស្ត និងរដ្ឋវៀតណាម សម្រេចដោយជោគជ័យនូវការធ្វើឧស្សាហូបនីយកម្ម និងទំនើបកម្មជាតិ។

៣. ភាគីទាំងពីរសម្តែងភាពរីករាយចំពោះការរីកចម្រើនដ៏ល្អប្រពៃនៃទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយរវាងកម្ពុជា និងវៀតណាមក្នុងរយៈពេលកន្លងមក ដែលបាននាំមកនូវផលប្រយោជន៍ជាក់ស្តែងជាច្រើនសម្រាប់ប្រជាជននៃប្រទេសទាំងពីរ។

ភាគីវៀតណាមបានសង្កត់ធ្ងន់ថា វៀតណាមបានវាយតម្លៃខ្ពស់ចំពោះមនោសញ្ចេតនាដ៏ជ្រាលជ្រៅ ការគាំទ្រដ៏មានតម្លៃ និងជំនួយឧបត្ថម្ភនានារបស់**ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ** ព្រះវររាជបិតានៃព្រះរាជាណាចក្រកម្ពុជា "**ព្រះបរមរតនកោដ្ឋ**" **ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** ថ្នាក់ដឹកនាំ និងប្រជាជនកម្ពុជា ដែលបានផ្តល់

ជូនប្រជាជន**វៀតណាម** ក្នុងបុព្វហេតុតស៊ូដើម្បីឯករាជ្យជាតិ កាលពីអតីតកាល ក៏ដូចជាការកសាង និងការអភិវឌ្ឍជាតិនាពេលបច្ចុប្បន្ន។

**កម្ពុជា**ក៏បានសម្តែងការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្រដ៏ខ្លាំងក្លា និងជំនួយឧបត្ថម្ភ ដែលថ្នាក់ដឹកនាំ និងប្រជាជន**វៀតណាម** ជាច្រើនជំនាន់បានផ្តល់ជូនប្រជាជន**កម្ពុជា** នាអតីតកាល និងក្នុងបច្ចុប្បន្នកាល និងបានបញ្ជាក់ថា ប្រជាជន**កម្ពុជា**តែងតែចងចាំចំពោះការជួយឧបត្ថម្ភរបស់កងទ័ពស្ម័គ្រចិត្ត**វៀតណាម** ដែលបានសហការជាមួយប្រជាជន**កម្ពុជា** ក្នុងការរំដោះ**កម្ពុជា** ចេញពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម នៅឆ្នាំ១៩៧៩។

៤. ភាគីទាំងពីរបានឯកភាពគ្នាថា ការពង្រឹង និងអភិវឌ្ឍទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងវៀតណាម ពិតជាមានសារៈសំខាន់សម្រាប់ប្រទេសទាំងពីរ។ ភាគីទាំងពីរនៅតែប្តេជ្ញាបន្តពង្រឹង និងពង្រីកទំនាក់ទំនងទ្វេភាគី ស្របតាមពាក្យស្លោក "**ភាពជាអ្នកជិតខាងល្អ មិត្តភាពជាប្រពៃណី កិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយ និងស្ថិរភាពយូរអង្វែង**" អនុវត្តយ៉ាងពេញលេញនូវគោលការណ៍ដែលមានចែងក្នុងសេចក្តីប្រកាសរួមកម្ពុជា-វៀតណាម ឆ្នាំ១៩៩៩ ឆ្នាំ២០០៥ ឆ្នាំ២០០៩ ឆ្នាំ២០១១ ឆ្នាំ២០១៤ ខែមិថុនា ឆ្នាំ២០១៦ និងខែធ្នូ ឆ្នាំ២០១៦ ដើម្បីគោរពគ្នាទៅវិញទៅមកនូវឯករាជ្យភាព អធិបតេយ្យភាព បូរណភាពទឹកដី មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងគ្នា និងមិនអនុញ្ញាតឱ្យមានកម្លាំងអមិត្រណាមួយប្រើប្រាស់ទឹកដីរបស់ខ្លួន ដើម្បីគំរាមកំហែងសន្តិសុខប្រទេសមួយទៀត និងដោះស្រាយរាល់បញ្ហាដែលកើតឡើងរវាងប្រទេសទាំងពីរដោយសន្តិវិធី។

៥. ភាគីទាំងពីរបានឯកភាពបង្កើនកិច្ចប្រជុំ និងការទាក់ទងកម្រិតខ្ពស់ ក៏ដូចជា ការផ្លាស់ប្តូរគណៈប្រតិភូនៅគ្រប់ជាន់ថ្នាក់ និងជំរុញឱ្យមានការប្រាស្រ័យទាក់ទងគ្នារវាងប្រជាជន និងប្រជាជន ជាពិសេសរវាងប្រជាជននៅតាមបណ្តាខេត្តជាប់ព្រំដែន។ ភាគីទាំងពីរបានឯកភាពធ្វើការយ៉ាងជិតស្និទ្ធ ដើម្បីអនុវត្តអោយមានប្រសិទ្ធភាពនូវបណ្តាកិច្ចព្រមព្រៀង និងសន្ធិសញ្ញារវាងប្រទេស និងរដ្ឋាភិបាលទាំងពីរ។ កិច្ចព្រមព្រៀង និងសន្ធិសញ្ញាទាំងនោះរួមមាន កំណត់ហេតុនៃកិច្ចប្រជុំលើកទី ១៥ នៃគណៈកម្មការចម្រុះកម្ពុជា-វៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ក៏ដូចជាសេចក្តីថ្លែងការណ៍រួម និងរបាយការណ៍នៃសន្និសីទស្តីពីកិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍រវាងបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម លើកទី៩ ដែលបានប្រព្រឹត្តទៅនៅភ្នំពេញ នាថ្ងៃទី១៣-១៥ ខែមីនា ឆ្នាំ២០១៧។

៦. ភាគីទាំងពីរបានឯកភាពគ្នាថា ការរៀបចំសកម្មភាពនានា ដើម្បីអបអរសាទរមិត្តភាពកម្ពុជា-វៀតណាម ឆ្នាំ២០១៧ ក្នុងឱកាសខួបលើកទី៥០ នៃការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ (២៤ មិថុនា

១៩៦៧ - ២៤ មិថុនា ២០១៧) ពិតជាមានសារៈសំខាន់ ក្នុងការលើកកម្ពស់ការយោគយល់គ្នារវាងប្រជាជនប្រទេសទាំងពីរ ជាពិសេសយុវជន អំពីមិត្តភាព និងសាមគ្គីភាពជាប្រពៃណីដ៏យូរអង្វែងរវាងប្រជាជនប្រទេសទាំងពីរ ដែលនឹងបញ្ជាក់ពីការទទួលខុសត្រូវរបស់ពួកគេក្នុងការពង្រឹង និងពង្រីកទំនាក់ទំនងនេះ។

៧. ភាគីទាំងពីរបានឯកភាពបន្តពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យនានា ជាពិសេស វិស័យដែលផ្តល់ផលប្រយោជន៍ដល់ប្រទេសទាំងពីរ ដូចជា ការអប់រំនិងបណ្តុះបណ្តាល ពាណិជ្ជកម្មតាមព្រំដែន ទេសចរណ៍ ទូរគមនាគមន៍ អាកាសចរស៊ីវិល ធនាគារ ប្រេងនិងឧស្ម័ន កៅស៊ូ កសិកម្ម និងថាមពលអគ្គិសនី ជាដើម និងព្យាយាមឱ្យបានខ្លាំងក្លាក្នុងការសម្រេចគោលដៅពាណិជ្ជកម្មទ្វេភាគី ៥ ពាន់លានដុល្លារ នាបណ្តាឆ្នាំខាងមុខ។ ក្នុងន័យនេះ ភាគីទាំងពីរបានប្តេជ្ញាជំរុញការធ្វើពាណិជ្ជកម្ម និងវិនិយោគនៅក្នុងទីផ្សារប្រទេសនីមួយៗ ដោយធានាឱ្យបាននូវសិទ្ធិ និងប្រយោជន៍ស្របច្បាប់របស់ពួកគេ។

៨. ភាគីទាំងពីរឯកភាពពង្រឹងកិច្ចសហប្រតិបត្តិការការពារការរត់ពន្ធឆ្លងកាត់ព្រំដែន និងការកេងបន្លំពាណិជ្ជកម្ម រួមបញ្ចូលទាំងការផលិត និងការរត់ពន្ធទំនិញក្លែងក្លាយនិងទំនិញខូចគុណភាព និងបញ្ចប់នីតិវិធីសាងសង់ផ្សារគំរូព្រំដែន ក្នុងឃុំដា ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ប្រទេសកម្ពុជា។

៩. ភាគីទាំងពីរបានបញ្ជាក់អះអាងសាជាថ្មីនូវការគោរព និងការអនុវត្តឱ្យបានពេញលេញនូវសន្ធិសញ្ញាកំណត់ព្រំដែន និងកិច្ចព្រមព្រៀងព្រំដែនពាក់ព័ន្ធដទៃទៀតរវាងរដ្ឋទាំងពីរ។ ភាគីទាំងពីរបានកោតសរសើរយ៉ាងជ្រាលជ្រៅចំពោះកិច្ចខិតខំប្រឹងប្រែងរបស់គណៈកម្មការចម្រុះខណ្ឌសីមា និងកំណត់ព្រំដែនគោក (JBC) ដែលសម្រេចបានប្រមាណ ៨៤% នៃការងារខណ្ឌសីមា និងបោះបង្គោលព្រំដែនគោកក្នុងរយៈពេលកន្លងមក ដោយឈរលើមូលដ្ឋាននៃសន្ធិសញ្ញាកំណត់ព្រំដែន រវាងប្រទេសទាំងពីរ។

ជាមួយនឹងសមិទ្ធផលទាំងនេះ ភាគីទាំងពីរបានបញ្ជាក់ពីការតាំងចិត្តបញ្ចប់ការងារដាំបង្គោលតម្រុយអចិន្ត្រៃយ៍ និងបង្គោលបំពេញបន្ថែម ក្នុងឆ្នាំ ២០១៧ ក៏ដូចជាការបញ្ចប់ និងអនុវត្តការខណ្ឌសីមា និងឯកសារខណ្ឌសីមាពាក់ព័ន្ធ ដោយយោងទៅលើការព្រមព្រៀងនៃគណៈកម្មការចម្រុះរវាងប្រទេសទាំងពីរក្នុងគោលបំណងចុះហត្ថលេខាឯកសារផ្លូវច្បាប់នេះ ដើម្បីទទួលស្គាល់ការសម្រេចបាន ៨៤% នៃការងារខណ្ឌសីមាព្រំដែនទាំងអស់ ក៏ដូចជា ស្វែងរកដំណោះស្រាយដែលអាចទទួលយកបានដោយភាគីទាំងពីរ ចំពោះបញ្ហាព្រំដែនដែលនៅសេសសល់ ដើម្បីបញ្ចប់ការងារខណ្ឌសីមាព្រំដែនគោក និងដំណើរការបោះបង្គោលព្រំដែនឲ្យបានឆាប់។ ភាគីទាំងពីរបានឯកភាពពង្រឹងការសម្របសម្រួលគ្នាក្នុងការ

គ្រប់គ្រងព្រំដែន ស្របតាមបទដ្ឋានគតិយុត្តិដែលមានស្រាប់ ស្របតាមទស្សនវិស័យការកសាងបន្ទាត់ព្រំដែនសន្តិភាព ស្ថិរភាព មិត្តភាព កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍប្រកបដោយចីរភាព។

១០. ភាគីទាំងពីរបានសន្យាបន្តបង្កលក្ខណៈងាយស្រួលដល់អណិកជនរបស់ប្រទេសមួយអាចរស់នៅលើទឹកដីនៃប្រទេសមួយទៀត ស្របតាមច្បាប់របស់ប្រទេសនោះ។ ក្នុងស្មារតីជាអ្នកជិតខាងដ៏ជិតស្និទ្ធ ភាគីវៀតណាមសង្ឃឹមថា ភាគីកម្ពុជានឹងបន្តចាត់វិធានការសមស្របនានា ក្នុងការធានាសិទ្ធិស្របច្បាប់របស់អណិកជនវៀតណាមនៅកម្ពុជា ដោយស្មើភាពអោយដូចជនបរទេសដទៃទៀត ដែលរស់នៅកម្ពុជា ស្របតាមច្បាប់ និងលិខិតបទដ្ឋានរបស់កម្ពុជា ដែលនឹងរួមចំណែកដល់ការពង្រឹង និងពង្រីកមិត្តភាពជាប្រពៃណីរវាងប្រទេសទាំងពីរ។

១១. ភាគីទាំងពីរអបអរសាទរចំពោះកិច្ចសហប្រតិបត្តិការដ៏ល្អក្នុងវេទិកាពហុភាគីនាអតីតកាល ជាពិសេសការគាំទ្រគ្នាទៅវិញទៅមកចំពោះបេក្ខភាពរបស់ប្រទេសនីមួយៗ ក្នុងអង្គការអន្តរជាតិសំខាន់ៗ។ ក្នុងបរិបទនៃការកើនឡើងនូវភាពស្មុគ្រស្មាញក្នុងតំបន់ និងសកលលោក ភាគីទាំងពីរបានឯកភាពបង្កើនកិច្ចសម្របសម្រួល ការចែករំលែកព័ត៌មាន និងការគាំទ្រគ្នាទៅវិញទៅមកក្នុងវេទិកាពហុភាគី។

ភាគីទាំងពីរបានឯកភាពគ្នាបន្តធ្វើការយ៉ាងជិតស្និទ្ធក្នុងក្របខណ្ឌអាស៊ាន តាមរយៈការខិតខំប្រឹងប្រែងរួមដើម្បីកសាងសហគមន៍អាស៊ានមួយ ដែលផ្អែកលើមូលដ្ឋានច្បាប់ ការយកចិត្តទុកដាក់លើប្រជាជន និងការយកប្រជាជនជាស្នូល ជាមូលដ្ឋាននៃរាល់ដំណើរការតំបន់។

ឆ្លៀតក្នុងឱកាសនេះ ឯកឧត្តមនាយករដ្ឋមន្រ្តី **ង្វៀន សួនហ៊្វុក** បានសម្តែងការជូនពរយ៉ាងស្មោះស្ម័គ្រ សូមឱ្យវេទិកាសេដ្ឋកិច្ចពិភពលោកស្តីពីអាស៊ាននាពេលខាងមុខដែលរៀបចំដោយកម្ពុជា ពីថ្ងៃទី១០-១២ ឧសភា ២០១៧ ទទួលបានជោគជ័យយ៉ាងធំធេង។

១២. ភាគីទាំងពីរបានបញ្ជាក់ពីសារៈសំខាន់នៃការថែរក្សាសន្តិភាព ស្ថិរភាព និងសន្តិសុខក្នុងសមុទ្រចិនខាងត្បូង ការដោះស្រាយជម្លោះដោយមធ្យោបាយសន្តិវិធី ការអត់ធ្មត់ ការជៀសវាងការគំរាមកំហែង និងការប្រើប្រាស់កម្លាំង ស្របតាមគោលការណ៍ច្បាប់អន្តរជាតិដែលទទួលស្គាល់ជាសាកល រួមមានអនុសញ្ញាអង្គការសហប្រជាជាតិឆ្នាំ១៩៨២ ស្តីពីច្បាប់សមុទ្រ (UNCLOS)។ ភាគីទាំងពីរបានប្តេជ្ញាធ្វើការយ៉ាងជិតស្និទ្ធក្នុងក្របខណ្ឌអាស៊ាន-ចិន ក្នុងការអនុវត្តយ៉ាងពេញលេញ និងមានប្រសិទ្ធិភាពនូវសេចក្តីថ្លែងការណ៍ស្តីពីក្រមប្រតិបត្តិនៃបណ្តាភាគីក្នុងសមុទ្រចិនខាងត្បូង (DOC) និងបញ្ចប់ឱ្យបានឆាប់នូវក្រមប្រតិបត្តិក្នុងសមុទ្រចិនខាងត្បូង (COC) រួមទាំងបញ្ចប់ក្របខណ្ឌនៃក្រមប្រតិបត្តិក្នុងសមុទ្រចិនខាងត្បូង (COC) ក្នុងពាក់កណ្តាលឆ្នាំ២០១៧។

១៣. ភាគីទាំងពីរបានសន្យាធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្នា និងជាមួយសមាជិកដទៃទៀតក្នុងក្របខណ្ឌគណៈកម្មការទន្លេមេគង្គ និងកិច្ចសហប្រតិបត្តិការមេគង្គដទៃទៀត ដើម្បីធានាការគ្រប់គ្រង និងការប្រើប្រាស់ធនធានទឹកក្នុងអាងទន្លេមេគង្គប្រកបដោយចីរភាព ស្របតាមច្បាប់ និងការអនុវត្តជាអន្តរជាតិ ក៏ដូចជាការធ្វើសុខដុមនីយកម្មនៃផលប្រយោជន៍របស់ប្រទេសជាប់ដងទន្លេ ក្នុងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពក្នុងតំបន់។

១៤. ភាគីទាំងពីរបានវាយតម្លៃខ្ពស់ចំពោះលទ្ធផលជាវិជ្ជមាន និងមានអត្ថន័យដ៏ជ្រាលជ្រៅចំពោះដំណើរទស្សនកិច្ចផ្លូវការរបស់ឯកឧត្តមនាយករដ្ឋមន្ត្រី **ង្វៀន សួនហ៊្វុក** នៅកម្ពុជា ដោយបានចាត់ទុកថា ជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយដ៏សំខាន់ ដែលរួមចំណែកជាវិជ្ជមានដល់ការជំរុញសាមគ្គីភាព មិត្តភាពជាប្រពៃណី កិច្ចសហប្រតិបត្តិការជាប្រពៃណីរវាងកម្ពុជា និងវៀតណាម ក៏ដូចជា ដើម្បីសន្តិភាព ស្ថិរភាព កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍនៅក្នុងតំបន់ និងពិភពលោក។

១៥. ឯកឧត្តមនាយករដ្ឋមន្ត្រី **ង្វៀន សួនហ៊្វុក** បានសម្តែងនូវការដឹងគុណយ៉ាងស្មោះស្ម័គ្រចំពោះការស្វាគមន៍ និងបដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅ ដែលថ្នាក់ដឹកនាំ និងប្រជាជនកម្ពុជា ជូនចំពោះគណៈប្រតិភូជាន់ខ្ពស់នៃរដ្ឋាភិបាលវៀតណាម ក្នុងកំឡុងពេលទស្សនកិច្ចនេះ។

១៦. ឯកឧត្តម **ង្វៀន សួនហ៊្វុក** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម បានអញ្ជើញ **សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** និងថ្នាក់ដឹកនាំនៃព្រះរាជាណាចក្រកម្ពុជា ទៅបំពេញទស្សនកិច្ចនៅប្រទេសវៀតណាម ក្នុងឱកាសឆ្នាំមិត្តភាពកម្ពុជា-វៀតណាម ២០១៧។ **សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** និងថ្នាក់ដឹកនាំកម្ពុជាបានសម្តែងអំណរគុណ និងទទួលសេចក្តីអញ្ជើញនេះ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៧